ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ប្រយុទ្ធនឹងជំងឺ អេដស៍ក្នុងចំណោមបុរសរួមភេទជាមួយបុរស និងស្រីស្រស់



ថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១

ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## ១. សេចក្តីផ្តើម

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពិសេសលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងចំណោមបុរសរួមភេទជាមួយបុរស និងស្រីស្រស់ បានសហការ និងគាំទ្រថវិកាដោយអង្គការថែទាំសុខភាពអ្នកជំងឺអេដស៍ (AHF : Impulse Phnom Penh) បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ខ្លួននៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

កិច្ចប្រជុំត្រូវដឹកនាំ និងសម្របសម្រួលដោយឯកឧត្តមវេជ្ជ. តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងចំណោមបុរសរួមភេទជាមួយបុរស និងស្រីស្រស់នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមពីសមាជិកក្រុមការងារ អាជ្ញាធរមូលដ្ឋាន មន្ត្រីលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ថ្នាក់ជាតិ អង្គការដែលធ្វើការងារជាមួយក្រុមប្រឈមមុខខ្ពស់ និងក្រុមគោលដៅ។

## ២. គោលបំណងនៃកិច្ចប្រជុំ

ការបង្ហាញពីលទ្ធផលសកម្មភាពការងារដោយសង្ខេបប្រចាំត្រីមាសទី១ក្នុងឆ្នាំ២០១៨ និងផ្តោតសំខាន់ៗលើបញ្ហាប្រឈមនានា ដើម្បីជាទុនក្នុងការរៀបចំផែនការសកម្មភាពឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់អនុវត្តក្នុងឆ្នាំ២០១៨។



## ៣. សមាជិកអង្គប្រជុំដែលបានចូលរួមមាន

- តំណាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តំណាងក្រសួងទេសចរណ៍
- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ទីប្រឹក្សាអនុរដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន
- អនុប្រធាននាយកដ្ឋាននៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- អនុប្រធាននាយកដ្ឋាន នៃក្រសួងការពារជាតិ
- នាយករងការិយាល័យ នៃក្រសួងមហាផ្ទៃ
- មន្ត្រីកម្មវិធីអេដស៍នៃមន្ទីរសុខាភិបាលរាជធានីភ្នំពេញ
- ប្រធានកម្មវិធី HACC
- អគ្គនាយករង MoLVT
- ប្រធានផ្នែក BCC នៃ NCHADs
- Impulse Coordinator នៃ AHF
- មន្ត្រីអប់រំសុខភាពនៃអង្គការ RHAC
- មន្ត្រីរដ្ឋបាលនៃក្រសួងអប់រំ យុវជន និងកីឡា

## ៤. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកា ដែលបានអញ្ជើញចូលរួមកិច្ចប្រជុំនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។ ឯកឧត្តមប្រធានអង្គប្រជុំបានមានប្រសាសន៍ថា៖ ជាមួយភាពជោគជ័យថ្មីៗ ដែលកម្ពុជាទទួលបានជាប្រទេសមួយក្នុងចំណោមប្រាំពីរប្រទេស ដែលសម្រេចបានគោលដៅ ៩០ ៩០ ៩០ មុនពេលកំណត់ក៏ដោយ ប៉ុន្តែតាមការ

ប៉ាន់ប្រមាណបែបវិទ្យាសាស្ត្ររបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគនៃក្រសួងសុខាភិបាល យើងនៅមានអ្នកជំងឺអេដស៍ ១២០០០នាក់ ទៀតមិនទាន់រកឃើញ ដែលទាមទារការសហការពីអាជ្ញាធរមូលដ្ឋាន មន្ត្រីមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ក្នុងការជួយស្វែងរក ពិសេសត្រូវខិតខំបន្តទៀត ដោយអប់រំផ្សព្វផ្សាយបង្ការមិនឱ្យមានការឆ្លងថ្មី និងស្វះស្វែងរកអ្នកចាស់ ដើម្បីទទួលការព្យាបាល។ ជាកិច្ចបន្តនៃការប្រជុំ ជាបទបង្ហាញពីលទ្ធផលសង្ខេបរបស់អង្គការជាដៃគូដែលអនុវត្តផ្ទាល់ជាមួយក្រុម បុរសរួមភេទជាមួយបុរស និងស្រីស្រស់។




*ប្រធានបទទី១. ការបង្ហាញពីលទ្ធផលសង្ខេបរបស់ Impulse Phnom Penh (AHF)*

តើអ្វីជា Impulse Phnom Penh? → ជាគម្រោងមួយរបស់អង្គការ AHF ដែលធ្វើការងារដោយមិនគិតពីផលកម្រៃលើក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ ក្នុងការជំរុញអប់រំផ្សព្វផ្សាយពីបញ្ហាសុខភាពផ្លូវភេទ ការប្រើប្រាស់ស្រោមអនាម័យ និងកម្មវិធីអេដស៍ ក្រោមការឧបត្ថម្ភដោយសហរដ្ឋអាមេរិក។ ចំពោះរបាយការណ៍សកម្មភាពដែលបានអនុវត្តកន្លងមកក្នុងឆ្នាំ២០១៧ និង២០១៨ រួមមាន៖

- ចំពោះសកម្មភាពក្នុងឆ្នាំ២០១៧កន្លងមករួមមាន
  - សកម្មភាពគម្រប់ខួប១ឆ្នាំដែលបានធ្វើឡើងនៅ Valentino Bistro and Club នៅខែឧសភា ឆ្នាំ២០១៧។
  - បានដាក់តាំងពិពណ៌រូបភាពមួយដែលមានឈ្មោះថា Live Shamelessly ដែលមានន័យថារស់នៅដោយគ្មានការលាក់បាំង ដែលជាសារមួយដើម្បីឲ្យក្រុមស្រលាញ់ភេទដូចគ្នាឲ្យមានភាពក្លាហានក្នុងការមករកសេវាតេស្តឈាម។

- សកម្មភាពផ្សព្វផ្សាយរបស់ Impulse Phnom Penh ដែលបានធ្វើឡើងនៅ Blue chilli gay bar ដែលមានការប្រឹក្សា និងសេវាតេស្តឈាមកើនរហូតដល់៥០% និងសកម្មភាពការចែកចាយស្រោម អនាម័យដល់ MSM/Gay បាន៧០% ដែលមាន MSM ចូលរួម៩០ទៅ១០០នាក់តាមរយៈការលេងហ្គេមអំពីការប្រើប្រាស់ស្រោម និង ការបង្ហាញម៉ូតសាច់ដុំ។
- កម្មវិធី Impulse Phnom Penh Soaked នៅ World Aids Day ដែលមានការចូលរួមពីក្រុម MSM/Gay ចំនួន៩០នាក់ និងបានទទួលសេវាតេស្តឈាមចំនួន៣០នាក់ហើយលទ្ធផលដែលទទួលបានគឺលទ្ធផលអវិជ្ជមានទាំងអស់។
- ផែនការយុទ្ធសាស្ត្រក្នុងការលុបបំបាត់ការរើសអើងអ្នកជំងឺអេដស៍សម្រាប់ឆ្នាំ២០១៧។
- អំពីយុទ្ធនាការផ្សព្វផ្សាយតាមរយៈ Social Media (Facebook Page) គិតរហូតដល់ឆ្នាំ២០១៧ មានអ្នកចូលរួម Like page រហូតដល់១៨,០០០នាក់ជាង។
- Award Letter Appreciation ការផ្តល់បណ្ណ័សរសើរក្នុងគោលបំណងលើកទឹកចិត្តដល់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងចំណោមបុរសស្រលាញ់បុរស និងស្រីស្រស់។

➢ សកម្មភាពក្នុងឆ្នាំ២០១៨ ក្នុងខែមករា និងកុម្ភៈ

- សកម្មភាពក្នុងការចែកស្រោមអនាម័យ និងកម្មវិធីផ្សព្វផ្សាយអប់រំតាមរយៈរូបថត អារយឺតនៅក្នុង Club និង Sauna Venues នៅខេត្តសៀមរាប។
- សកម្មភាពសិក្ខាសាលាជាមួយ NGOs និង NAA ក្នុងគោលបំណងកែលំអទៅលើ work plan និង Technical សម្រាប់ MSM/TG TWG។
- មានការប្រជុំជាមួយក្រុមការងារស្ម័គ្រចិត្តរបស់ Impulse ៤ទៅ៥ដងក្នុង១ខែ ដើម្បីបង្កើនទំនាក់ទំនងជាមួយពួកគាត់ និងស្វែងរកគំនិតថ្មីៗ។
- សម្រាប់គម្រោង International Condom Day ក្នុងឆ្នាំ២០១៨ ដែលបានធ្វើឡើងក្នុងថ្ងៃទី១១ខែកុម្ភៈ ឆ្នាំ២០១៨ នៅ Jet Container (កោះពេជ្រ) ដោយមានការប៉ាន់ប្រមាណចំនួនអ្នកចូលរួម ដែល៧០%គឺជា MSM/Gay ហើយមានការចែកស្រោមអនាម័យផងដែរ។

- o សកម្មភាពក្នុងខែ០២ និងខែ០៣ គឺធ្វើការផ្លាស់ប្តូរ Zero Discrimination ទៅជា Zero stigma (បង្កើនក្តីស្រលាញ់ដើម្បីជម្រុញការលើកទឹកចិត្ត) ក្នុងគោលបំណងលុបបំបាត់ការរើសអើង និងជម្រុញឲ្យពួកគេមកទទួលសេវាតេស្តឈាមផងដែរ។
- o ផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៨
  - ដោយគម្រោង Impulse នៅភ្នំពេញមានការស្គាល់ច្រើន ដូចនេះនឹងមានផែនការទៅខេត្តសៀមរាប និងបាត់ដំបង ដើម្បីឲ្យក្រុមបង្គោលស្គាល់ពី Impulse ផងដែរ។
  - Quartery meeting with NAA (ធ្វើបទបង្ហាញអំពី SOGIE ដែលទាក់ទង MSM និង HIV)។
  - Bi-gathering ។
  - Reflection workshop។
  - Campaign and Advocacy ។
  - Asian Retreat Submit។



*ប្រធានបទទី២ . បទបង្ហាញពីផែនការសកម្មភាព និងរបាយការណ៍វឌ្ឍនភាពនៃអង្គការ RHAC ទៅលើក្រុមអ្នកបំលែងភេទ TG (Transgender)*

- o ចក្ខុវិស័យ
  - ផ្តល់សេវាដែលមានទំនុកចិត្តបំផុតជូនអតិថិជន។
  - ក្នុងឆ្នាំ២០២២នឹងផ្តល់សេវាប្រកបដោយគុណភាព ហើយប្រែក្លាយជាមជ្ឈមណ្ឌលផ្តល់សេវាសុខភាពស្ត្រី។

- បេសកកម្ម
  - បង្កលក្ខណៈឲ្យប្រជាពលរដ្ឋទទួលបាននូវសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចនូវសុខភាព និងជីវិតសមស្របទៅតាមសេវាគំរូ ដោយផ្តោតលើសុខភាពគ្រួសារ រួមទាំងសុខភាពបន្តពូជ សុខភាពផ្លូវភេទ សុខភាពមាតានិងទារក និងជំងឺអេដស៍ផងដែរ។
  - ផ្តល់សេវាប្រកបដោយទំនុកចិត្តដល់ក្រុមបំលែងភេទ ដោយផ្តោតទៅលើសេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទតាមរយៈការផ្តល់ប្រឹក្សា។
- សកម្មភាពសំខាន់ៗ
  - ការសិក្សាស្រាវជ្រាវស្តីពីសុខភាពអ្នកបំលែងភេទ។
  - សិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីបង្កើតសៀវភៅណែនាំសម្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អង្គការរ៉ាក់។
  - បណ្តុះបណ្តាលដល់អ្នកផ្តល់សេវារបស់គ្លីនិចរ៉ាក់ និងបុគ្គលិកគម្រោង។
  - សហការជាមួយអង្គការដៃគូ ដើម្បីបញ្ជូនអ្នកបំលែងភេទទៅទទួលសេវានៅគ្លីនិចរ៉ាក់ និងផ្តល់សេវាកម្មគ្លីនិចដោយឥតគិតថ្លៃដល់អ្នកបំលែងភេទសម្រាប់រយៈពេល៣ឆ្នាំ(២០១៤ ដល់ ២០១៦)។
  - ការបោះពុម្ពសម្ភារអប់រំផ្សព្វផ្សាយនៅគ្លីនិចរ៉ាក់។
  - រៀបចំវេទិកាអ្នកបំលែងភេទប្រចាំឆ្នាំ។
  - រៀបចំសិក្ខាសាលាស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រដល់អ្នកពាក់ព័ន្ធ។
- ការផ្តល់សេវាដល់អ្នកបំលែងភេទ
  - STI diagnose: កំនត់រោគសញ្ញានៃជំងឺកាមរោគ។
  - STI treatment: ការព្យាលជំងឺកាមរោគ។
  - VCCT: តេស្តឈាមរកមេរោគអេដស៍។
  - Primary Health Care: ពិនិត្យ និងព្យាបាលជំងឺទូទៅ។
  - Wart: ពិនិត្យ និងព្យាបាលជំងឺដុះសាច់លើប្រដាប់បន្តពូជ។
- ផលវិបាកក្នុងអំឡុងពេលផ្តល់សេវា
  - ក្រុមគោលដៅមានចំណេះដឹងទាប ពិបាកក្នុងការពិគ្រោះយោបល់ និងការណាត់ជួបមានភាពយឺតយ៉ាវមិនទាន់ពេលវេលា។

*ប្រធានបទទី៣ . បទបង្ហាញពីផែនការសកម្មភាព និងការអនុវត្តគម្រោង Wisdom & SOGIE របស់អង្គការ KHANA*



- គោលបំណងនៃគម្រោង
  - កសាងសមត្ថភាពរបស់ក្រុមស្រលាញ់ភេទដូចគ្នា ក្នុងគោលបំណងស្វែងរកការគាំទ្រដើម្បីឲ្យអ្នកស្រលាញ់ភេទដូចគ្នាឲ្យចេះប្រមូលរាល់បញ្ហារបស់ពួកគាត់ ដើម្បីយកទៅដដែកជាមួយនឹងតំណាងរបស់គាត់(អាជ្ញាធរមូលដ្ឋាន ឬមណ្ឌលសុខភាព)។
- គោលដៅ
  - ជម្រុញទំនាក់ទំនង និងសកម្មភាពចលនារបស់សហគមន៍ឲ្យចេះស្វែងយល់ពីបញ្ហារបស់ពួកគាត់ និងចូលរួមដោះស្រាយបញ្ហារបស់ពួកគាត់ និងរុករកឱ្យឃើញក្រុមប្រឈមមុខខ្ពស់បំផុតទៅនឹងការឆ្លងមេរោគអេដស៍ជួយផ្តល់សេវាបង្កើនសេវាឱ្យខ្លាំងក្លា និងរក្សាបន្តឱ្យនៅក្នុងសេវា (IRIR) ដើម្បីរួមចំណែកដល់ការសម្រេចឱ្យបានដល់គោលដៅថ្នាក់ជាតិ ៩០-៩០-៩០នៅឆ្នាំ២០២០។
- សកម្មភាពសំខាន់ៗ

- ពង្រឹងសំលេងសហគមន៍ (បញ្ហាឬតម្រូវការផ្សេងៗ): ត្រូវមានការចូលរួមឲ្យបានពេញលេញដោយត្រូវមានជាតំណាងឲ្យបានពិតប្រាកដ និងមានសមត្ថភាពក្នុងការធ្វើបទបង្ហាញ ឬជំនាញពិតប្រាកដ។

- គំនិតផ្តួចផ្តើមដើម្បីស្វែងរកការគាំទ្រ: ការបង្កើតជាកិច្ចសន្ទនាចងក្រងជាឯកសារតស៊ូមតិ និងការពង្រឹងសិទ្ធិអំណាចនៅក្នុងសហគមន៍។
- ការកសាងនិងពង្រឹងសមត្ថភាព: បង្កើតជាវគ្គបណ្តុះបណ្តាលលើសេវាគាំទ្រសង្គម និងវេទិកាសិក្សា និងការចែករំលែកផ្សេងៗ។

○ លទ្ធផលសម្រេចបានសំខាន់ៗ

- ទទួលបានក្រុមគោលដៅដែលចូលរួមបាន២០ជនបង្គោលក្នុងការពង្រឹងការងារសហគមន៍ ឬផ្តល់ជំនួយទាក់ទងការងារបច្ចេកទេស។
- បានបង្កើតកិច្ចសន្ទនារវាងអ្នកតំណាងអ្នកស្រលាញ់ភេទដូចគ្នាជាមួយអាជ្ញាធរពាក់ព័ន្ធ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)។

○ ការកសាងសមត្ថភាព

- មានវគ្គបណ្តុះបណ្តាលស្វែងរកការគាំទ្រជាមួយអាជ្ញាធរមូលដ្ឋាន។
- មានវគ្គបណ្តុះបណ្តាលស្តីពីសេវាគាំទ្រសង្គមសម្រាប់អ្នកស្រលាញ់ភេទដូចគ្នា ដល់ជនបង្គោល។
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់តំបន់ដោយមានតំណាងអ្នកស្រលាញ់ភេទដូចគ្នាក្នុងកិច្ចប្រជុំថ្នាក់ក្រោមជាតិ។

○ ឧបសគ្គ

- ទាក់ទងនឹងការចូលរួមមានការពិបាក ចំពោះភូមិឃុំមួយចំនួនមិនចូលរួមទទួលបានការបណ្តុះបណ្តាល។
- កង្វះខាតឯកសារចាំបាច់មួយចំនួនពេលចុះអនុវត្តន៍គម្រោង។
- បរិយាកាសគាំទ្រ មិនទាន់បានល្អប្រសើរ ដោយមានការចូលរួមរបស់អាជ្ញាធរពាក់ព័ន្ធ។

○ អនុសាសន៍

- ដាក់បញ្ចូលក្រុមអ្នកស្រលាញ់ភេទដូចគ្នាក្នុងសង្គម និងទាមទារឲ្យមានការពិភាក្សាយ៉ាងស៊ីជម្រៅលើគោលការណ៍និងវិធីសាស្ត្រច្បាស់លាស់ក្នុងការធ្វើការរួមគ្នារវាងអ្នកស្រលាញ់ភេទដូចគ្នានៅតាមសហគមន៍ ជាមួយស្ថាប័នអង្គការ ឬបណ្តាញ និងស្ថាប័ន រដ្ឋាភិបាលដែលពាក់ព័ន្ធនានា។

- បន្តការរៀបចំកិច្ចសន្ទនារវាងអ្នកស្រលាញ់ភេទដូចគ្នានៅតាមសហគមន៍ និងអាជ្ញាធរពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាមួយនឹងយន្តការតាមដានដាក់លាក់ក្នុងការដាក់បញ្ចូលបញ្ហា របស់អ្នកស្រលាញ់ភេទដូចគ្នា។
- ត្រូវប្រាកដឲ្យបានថាបុគ្គល និងក្រុមគ្រួសារអ្នកស្រលាញ់ភេទដូចគ្នាទទួលបានសៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណជាតិ និងលិខិតឆ្លងដែនដែលបានបង្ហាញពីអត្តសញ្ញាណយែនឌ័រ ឬភាពជាក់ស្តែង នៃទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ពួកគេ។

- មេរៀនទទួលបាន
  - ការវិនិយោគលើក្រុមអ្នកស្រលាញ់ភេទដូចគ្នាក្នុងសហគមន៍គឺជាយន្តការជួយជម្រុញ និងលើកកម្ពស់សកម្មភាពរបស់ពួកគេកាន់តែខ្លាំងក្លាក្នុងការបង្ហាញនៅបញ្ហារបស់ពួកគេ និងតម្រូវការរបស់ពួកគេ។
  - គោលគំនិតនៃអត្តសញ្ញាណយែនឌ័រ និងនិន្នាការភេទត្រូវបានដាក់បញ្ចូលទៅដល់គ្រប់មូលដ្ឋាន។
  - បង្កើតឲ្យមានវេទិកាដូចជា កិច្ចសន្ទនា និងពិភាក្សារវាងអាជ្ញាធរមូលដ្ឋានជាមួយអ្នកស្រលាញ់ភេទដូចគ្នាក្នុងសហគមន៍ដើម្បីធានាថាបញ្ហា និងតម្រូវការរបស់ពួកគេត្រូវបានដឹង និងយកចិត្តទុកដាក់ ក្នុងការចូលរួមដោះស្រាយបញ្ហា។

- អត្ថន័យរបស់ពាក្យ SOGIE
  - និន្នាការភេទ Sexual Orientation: ជាការបង្កើតឡើងនូវអារម្មណ៍ ឬការទាក់ទាញអារម្មណ៍ផ្លូវភេទចំពោះនរណាម្នាក់ដែលមានភេទផ្ទុយគ្នាភេទដូចគ្នា ឬអ្នកស្រលាញ់ទាំងពីរភេទ។
  - អត្តសញ្ញាណយែនឌ័រ Gender Identity: បុគ្គលម្នាក់មានអារម្មណ៍យ៉ាងជ្រាលជ្រៅចំពោះផ្នែកខាងក្នុងដោយផ្តោតទៅលើយែនឌ័ររបស់ពួកគេដែលទាក់ទង និងមិនទាក់ទងអំពីភេទកំណើត។
  - ការស្តែងចេញយែនឌ័រ Gender Expression: ជារបៀបដែលបុគ្គលម្នាក់សម្តែងនូវយែនឌ័រផ្ទាល់ខ្លួនទៅកាន់ពិភពខាងក្រៅដូចជា តាមរយៈសម្លៀកបំពាក់ របៀបដើរ ការនិយាយប្រាស្រ័យទាក់ទង តួនាទីសង្គម និងឥរិយាបថទូទៅ។

- ពាក្យគន្លឹះសម្រាប់អ្នកស្រលាញ់ភេទដូចគ្នា
    - បុរសស្រលាញ់ភេទដូចគ្នា (GAY): សំដៅទៅលើការទាក់ទាញភេទជាមួយនឹងភេទដូចគ្នា ឥរិយាបថផ្លូវភេទចំពោះភេទដូចគ្នា និងអត្តសញ្ញាណវប្បធម៌របស់មនុស្សភេទដូចគ្នាជាទូទៅ។
    - ស្រីស្រលាញ់ស្រី (LESBAIN): ស្ត្រីដែលមានភាពទាក់ទាញផ្លូវភេទ និងមានសមត្ថភាពបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយនឹងស្ត្រីដទៃទៀត។
    - អ្នករួមទាំងពីរភេទ (BI-SEXUAL): សំដៅលើបុគ្គលដែលមានភាពទាក់ទាញ ឬរួមភេទជាមួយ បុរសផង និងជាមួយស្ត្រីផង។
    - អ្នកប្តូរភេទឬប្តូរយែនឌ័រ (TRANSGENDER): ជាអ្នកដែលមានអត្តសញ្ញាណយែនឌ័រដែលខុសពីភេទកំណើតរបស់ខ្លួនដោយប្តូរពីប្រុសទៅជាស្រី (រូបរាងជាស្រី) ឬប្តូរពីស្រីទៅជាប្រុស (រូបរាងជាប្រុស) ការប្តូរយែនឌ័រមិនមែនជាចំណង់ចំណូលចិត្តក្នុងការរួមភេទនោះទេ។ អ្នកប្តូរយែនឌ័រអាចមានចំណង់ចំណូលចិត្ត ក្នុងការរួមភេទអ្វីក៏បាន។

## ៥. អនុសាសន៍ និងផែនការបន្ទាប់



*<u>ទិសដៅបន្ទាប់និងសកម្មភាពអនុវត្តបន្ត</u>*

១.ស្នើសុំឲ្យមានការទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋានដើម្បីងាយស្រួលចុះអប់រំផ្សព្វផ្សាយឲ្យបានទូលំទូលាយនៅក្នុងសហគមន៍។

២. ដោយសារការងាររបស់យើងមានសកម្មភាពច្រើន នៅចំពេលរដូវកាលបោះឆ្នោត ដូច្នេះស្នើសុំឲ្យផ្តល់ឯកសាររបាយការណ៍ដែលជាសមិទ្ធផលនៃការប្រយុទ្ធជំងឺអេដស៍នៅកម្ពុជាដែលរៀបរាងដោយអង្គការ RHAC និងកម្មវិធី Impulse មកលេខាធិការដ្ឋាននៃក្រុមការងារ។

៣. ស្នើសុំដល់គ្រប់អង្គការដែលជាដៃគូ ផ្តល់ជារូបថតនៅពេលចុះផ្សព្វផ្សាយ ឬបណ្តុះបណ្តាលកម្មវិធីផ្សេងៗ ដើម្បីយកមកដាក់តាំងនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤. ស្នើសុំខាងលេខាធិការដ្ឋាន ប្រមូលកម្មវិធីទាំងអស់ ដែលទទួលខុសត្រូវលើការងារ MSM/TG របស់ដៃគូពាក់ពន្ធ័ សម្រាប់យកមកបង្ហាញក្នុងកិច្ចប្រជុំ Technical Board។

៥. ស្នើដល់ Impulse , M style និង KHANA បង្កើតកម្មវិធីបណ្តុះបណ្តាលដល់ថ្នាក់ជាតិដើម្បីលុបបំបាត់ការរើសអើង និងបង្កើតឲ្យមានជនបង្គោលនៅតាមវិស័យអាទិភាព។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១២និង០០នាទីថ្ងៃត្រង់ នៅថ្ងៃខែ និងឆ្នាំដដែលក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨

អ្នកធ្វើរបាយការណ៍

បានឃើញ និងពិនិត្យត្រឹមត្រូវ

ប្រធាននាយកដ្ឋាន ប.ថ.គ

បានឃើញ និងឯកភាព

អគ្គលេខាធិការ